

# កម្ពុជា និងការបើក ទីផ្សារពិភពលោក តាមរយៈកិច្ចព្រមព្រៀង ពាណិជ្ជកម្មសេរី

Australian Aid

CAVAC Innovation in Agriculture

# អារម្ភកថា

ចាប់តាំងពីចូលជាសមាជិកអាស៊ានតាំងពីឆ្នាំ១៩៩៩ និងអង្គការពាណិជ្ជកម្មពិភពលោកក្នុងឆ្នាំ២០០៤ រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការបន្តធ្វើពិពិធកម្មសេដ្ឋកិច្ចនិងទីផ្សារ ដោយបានចូលរួមយ៉ាងសកម្មក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចតំបន់និងសកល ជាពិសេសបានដាក់ចេញនៅក្នុង "យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤" របស់រាជរដ្ឋាភិបាល នីតិកាលទី៦ និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ដែលជាយុទ្ធសាស្ត្រក្នុងការតម្រង់ទិសនូវការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា តាមរយៈការពន្លឿនការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច ការពង្រឹងបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងការផលិត និងនាំចេញទំនិញទៅកាន់ទីផ្សារអន្តរជាតិ សំដៅសម្រេចបាននូវចក្ខុវិស័យកម្ពុជាក្នុងការក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់ក្នុងឆ្នាំ២០៥០។

ក្នុងទិសដៅនេះ ក្រសួងពាណិជ្ជកម្មបាននិងបន្តផ្តោតការយកចិត្តទុកដាក់ខ្ពស់ និងបានសហការយ៉ាងជិតស្និទ្ធជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការបន្តស្វែងរកទីផ្សារថ្មីៗបន្ថែម តាមរយៈការចរចាបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទាំងថ្នាក់តំបន់ និងទ្វេភាគី ដែលមានលក្ខណៈអចិន្ត្រៃយ៍ និងផ្អែកលើគោលការណ៍ច្បាប់ ជាជាងពឹងផ្អែកលើភាពអនុគ្រោះពន្ធដែលមានលក្ខណៈឯកតោភាគី។ សូមរំលឹកផងដែរថា ចាប់តាំងពីកម្ពុជាចូលជាសមាជិកអាស៊ានក្នុងឆ្នាំ១៩៩៩ និងសមាជិកអង្គការពាណិជ្ជកម្មពិភពលោកក្នុងឆ្នាំ២០០៤ កម្ពុជាក៏បានចូលរួមយ៉ាងសកម្មជាមួយប្រទេសសមាជិកអាស៊ានក្នុងការចរចាបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ានបូកមួយ ជាមួយប្រទេសដៃគូសន្ទនាអាស៊ាន រួមមាន ចិន ជប៉ុន កូរ៉េខាងត្បូង ឥណ្ឌា អូស្ត្រាលី និងនូវែលសេឡង់ ផងដែរ។

ជាមួយគ្នានេះផងដែរ ក្នុងពេលថ្មីៗនេះ ក្រសួងពាណិជ្ជកម្មបានដឹកនាំចូលរួមចរចា និងបានសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័ន និងវិស័យឯកជនពាក់ព័ន្ធ ដោយសម្រេចបានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីថ្មីៗ រួមមាន កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (អាសិប) កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-ចិន និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-កូរ៉េ។ ក្រៅពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីខាងលើ បច្ចុប្បន្នក្រសួងពាណិជ្ជកម្មក៏បាននិងកំពុងដឹកនាំការចរចាជាមួយប្រទេសជាដៃគូសំខាន់ៗផ្សេងៗទៀត មានជាអាទិ៍ សហភាពសេដ្ឋកិច្ចអឺរ៉ុបអាស៊ី ឥណ្ឌា រុស្ស៊ី ជប៉ុន ម៉ុងហ្គោលី និងអេមីរ៉ាតអារ៉ាប់រួម ជាដើម សំដៅបន្តធ្វើពិពិធកម្មសេដ្ឋកិច្ចនិងទីផ្សារ ក៏ដូចជាដើម្បីជំរុញការនាំចេញផលិតផលកម្ពុជា និងជំរុញកំណើនសេដ្ឋកិច្ចជាតិ។

ទោះជាយ៉ាងណាក៏ដោយ ការរីករាលដាលនៃជំងឺកូវីដ-១៩ ក៏ដូចជាវិបត្តិសកលនៃបម្រែបម្រួលអាកាសធាតុ និងវិបត្តិនៃការឡើងថ្លៃប្រេងនិងឧស្ម័ន បានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើសេដ្ឋកិច្ចសកលលោក រួមទាំងកម្ពុជាផងដែរ។ ការរក្សាបាននូវប្រព័ន្ធពាណិជ្ជកម្មពហុភាគីដោយផ្អែកលើគោលការណ៍ច្បាប់ ពិតជាមានសារៈសំខាន់ណាស់ក្នុងការស្តារសេដ្ឋកិច្ចតំបន់និងសកលលោកឡើងវិញ។ ការសម្រេចបានកិច្ចព្រមព្រៀងអាសិប ដែលជាកិច្ចព្រមព្រៀងពាណិជ្ជកម្មដ៏ធំបំផុតលើពិភពលោក ដែលមានសមាជិកចំនួន១៥ប្រទេស រួមមានប្រទេសអាស៊ានទាំង១០ អូស្ត្រាលី ចិន ជប៉ុន កូរ៉េ និងនូវែលសេឡង់ នឹងចូលរួមចំណែកក្នុងការជំរុញ និងស្តារសេដ្ឋកិច្ចតំបន់ឡើងវិញបានឆាប់រហ័ស។ កិច្ចព្រមព្រៀងនេះ គ្របដណ្តប់លើទីផ្សារដែលមានប្រជាជន ២,២ ប៊ីលាននាក់ ស្មើនឹង ៣០% នៃប្រជាជនពិភពលោក ជាមួយផលិតផលក្នុងស្រុកសរុប ២៦,២ ទ្រីលានដុល្លារ ឬ ៣០% នៃផលិតផលក្នុងស្រុកសរុបសកលលោក និងប្រមាណជា ២៨% នៃពាណិជ្ជកម្មសកល នៅឆ្នាំ២០១៩។ ផ្អែកតាមលទ្ធផលនៃការចរចា និងការសិក្សារបស់វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីបូព៌ា (ERIA) បានបង្ហាញថា បន្ទាប់ពីបញ្ចប់កិច្ចព្រមព្រៀងអាសិប កម្ពុជាអាចនឹងមានកំណើនប្រចាំឆ្នាំនូវការនាំចេញចំនួន ៧,៣% ការវិនិយោគចំនួន ២៣,៤% និងផលិតផល

ក្នុងស្រុកសរុបប្រមាណ ២% លើផលិតផលក្នុងស្រុកសរុបដែលមានបច្ចុប្បន្ន។ ជាមួយគ្នានេះដែរ តាមការសិក្សារួមគ្នារបស់អ្នកជំនាញនៃវិទ្យាស្ថាន ERIA ជាមួយក្រុមការងារស្រាវជ្រាវរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ដែលបានបោះពុម្ពផ្សាយនាពេលថ្មីៗនេះ បានបង្ហាញថា កម្ពុជាអាចនឹងមានកំណើនប្រចាំឆ្នាំការនាំចេញក្នុងរង្វង់ប្រមាណពី ៩,៤% ទៅ ១៨% ដែលនឹងចូលរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចជាតិបន្ថែមប្រចាំឆ្នាំប្រមាណពី ២% ទៅ ៣,៨% កំណើនឱកាសការងារប្រចាំឆ្នាំប្រមាណ ៣,២% ទៅ ៦,២% និងកំណើនចំណូលពន្ធប្រចាំឆ្នាំប្រមាណ២% ទៅ ៣,៩% ផងដែរ។ ក្រៅពីនេះ កិច្ចព្រមព្រៀងអាសិបបង្កើតជាក្របខ័ណ្ឌ គតិយុត្តទំនើបថ្មី ដែលជំរុញការធ្វើកំណែទម្រង់ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធ ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និងស្ថាប័នដើម្បីធានាស្តង់ដារខ្ពស់របស់កម្ពុជានាពេលខាងមុខ ស្របពេលដែលកម្ពុជាអាចនឹងចាកចេញពីឋានៈប្រទេសអភិវឌ្ឍន៍តិចតួចក្នុងពេលឆាប់ៗខាងមុខ និងដើម្បីសម្រេចបានគោលដៅនៃចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និងឆ្នាំ២០៥០ ប្រកបដោយប្រសិទ្ធភាពផងដែរ។

ចុងបញ្ចប់ ខ្ញុំសូមកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះ ឯកឧត្តម **ស៊ីម សុខេង** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និងជាប្រធានគណៈកម្មាធិការចរចាកិច្ចព្រមព្រៀងអាសិបសម្រាប់កម្ពុជា ឯកឧត្តម **កៅ កោសល** អគ្គនាយកនៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម និងក្រុមការងារបច្ចេកទេសនៃនាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម ដែលបានដឹកនាំនិងខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តក្នុងការរៀបចំ និងចងក្រងឯកសារដ៏មានតម្លៃនេះ ដែលនឹងផ្តល់អត្ថប្រយោជន៍ច្រើនដល់សាធារណជន ជាពិសេស សហគ្រាសធុនតូច និងមធ្យម ឱ្យបានយល់កាន់តែច្បាស់ពីការធ្វើពិពិធកម្មទីផ្សារ និងជាពិសេសកិច្ចព្រមព្រៀងអាសិប។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងការបរទេស និងពាណិជ្ជកម្ម របស់រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា-អូស្ត្រាលី (CAVAC) ដែលតែងតែសហការនិងគាំទ្រក្រសួងពាណិជ្ជកម្មក្នុងពេលកន្លងមក។ ខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះក្រសួង ស្ថាប័ន និងវិស័យឯកជនពាក់ព័ន្ធ ក្នុងការសហការយ៉ាងជិតស្និទ្ធក្នុងការងារជំរុញពាណិជ្ជកម្ម និងការធ្វើពិពិធកម្មទីផ្សារនាំចេញរបស់កម្ពុជា។

ថ្ងៃ ចន្ទ ៣កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

# មាតិកា


**១. ការជំរុញពាណិជ្ជកម្មសកល** ០១

**២. កម្ពុជា និងសមាហរណកម្មសេដ្ឋកិច្ច** ០២

២.១ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងតំបន់ ០២

២.២ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី ០៣

២.២.១ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-ចិន ០៣

២.២.២ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-កូរ៉េ ០៣

**៣. កម្ពុជា និងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ ( អាសិប )** ០៤

៣.១ ទិដ្ឋភាពទូទៅ និងលក្ខណៈពិសេសនៃកិច្ចព្រមព្រៀងអាសិប ០៤

៣.២ បច្ច័យសក្តានុពលរបស់កិច្ចព្រមព្រៀងអាសិប មកលើសេដ្ឋកិច្ចកម្ពុជា ០៥

៣.៣ ចំណុចសង្ខេបនៃជំពូកសំខាន់ៗរបស់កិច្ចព្រមព្រៀងអាសិប ០៦

៣.៣.១ ពាណិជ្ជកម្មទំនិញ ០៦

៣.៣.២ វិធានដើមកំណើតទំនិញ ០៦

៣.៣.៣ នីតិវិធីគយ និងកិច្ចសម្រួលពាណិជ្ជកម្ម ០៧

៣.៣.៤ វិធានការអនាម័យ និងភូតគាមអនាម័យ ០៨

៣.៣.៥ ស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃអនុលោមភាព ០៨

៣.៣.៦ ឧបាស្រ័យពាណិជ្ជកម្ម ០៩

៣.៣.៧ ពាណិជ្ជកម្មសេវាកម្ម ១០

៣.៣.៨ វិនិយោគ ១១

៣.៣.៩ កម្មសិទ្ធិបញ្ញា ១១

៣.៣.១០ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ១១

៣.៣.១១ ការប្រកួតប្រជែង ១២

៣.៣.១២ សហគ្រាសធុនតូច និងមធ្យម ១២

៣.៣.១៣ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស ១២




# ១. ការជំរុញពាណិជ្ជកម្មសកល

រាជរដ្ឋាភិបាលបានជំរុញពាណិជ្ជកម្មជាសកលតាមរយៈ

ការដាក់ចេញនូវ "យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤" របស់រាជរដ្ឋាភិបាល នីតិកាលទី៦ ដែលបានតម្រង់ទិសការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា តាមរយៈការពន្លឿនពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចនិងការពង្រឹងភាពប្រកួតប្រជែង។



ការដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ២០១៥-២០២៥ (IDP) ដែលជាយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចថ្មីដើម្បីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា។

ការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងសេដ្ឋកិច្ចតំបន់និងសកលតាមរយៈ ការពង្រឹងសមត្ថភាពផលិតកម្ម ការផ្គត់ផ្គង់ទំនិញនិងសេវាកម្ម ការបន្តធ្វើពិពិធកម្មទំនិញនាំចេញឱ្យបានសម្បូរបែបជាងមុន និងការចរចាធ្វើពិពិធកម្មទីផ្សារនាំចេញ។



ការរៀបចំពង្រឹងខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថលនិងបដិវត្តន៍ឧស្សាហកម្មទី៤តាមរយៈ (១) ការកសាងបន្ថែមនូវលិខិតបទដ្ឋានច្បាប់ពាណិជ្ជកម្ម (២) ការកសាងធនធានមនុស្ស និង (៣) ការពង្រឹងសមត្ថភាពរបស់វិស័យឯកជនព្រមទាំងជំរុញការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់។



ការកែលម្អការធ្វើពាណិជ្ជកម្មតាមព្រំដែនការសម្រួលពាណិជ្ជកម្មជាមួយប្រទេសជិតខាងឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីធានាបាននូវការនាំចេញកសិផល និងផលិតផលកែច្នៃហើយប្រកបដោយនិរន្តរភាពនិងភាពរលូន។



ការដាក់ចេញនូវយុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីជំរុញការលូតលាស់ដោយចីរភាពនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក តាមរយៈការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពរបស់វិស័យសាធារណៈ សំដៅធ្វើឱ្យប្រសើរឡើងនូវបរិយាកាសអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងតាមរយៈការអនុវត្តផែនការសកម្មភាពដែលមានភាពប្រទាក់ក្រឡា និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់វិស័យនេះ។



# ២. កម្ពុជា និងសមាហរណកម្មសេដ្ឋកិច្ច

## ២.១ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងតំបន់



កម្ពុជាបានចូលជាសមាជិកអាស៊ាន ( ASEAN ) កាលពីឆ្នាំ១៩៩៩ដោយបានចូលរួមយ៉ាងសកម្ម រហូតបានប្រែក្លាយជាសហគមន៍សេដ្ឋកិច្ចអាស៊ាន ( ASEAN Economic Community ) កាលពីឆ្នាំ២០១៥ ដែលប្រទេសសមាជិកទាំងអស់កាត់បន្ថយពន្ធគយសូន្យចំនួន ៩៩,៦៥% នៃបន្ទាត់ពន្ធគយសរុប លើកលែងប្រទេស CLMV ពី 0-៥% សម្រាប់ ៩៨,៨៦% នៃបន្ទាត់ពន្ធគយសរុប



កម្ពុជាបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) កាលពីឆ្នាំ២០០៤ ដោយអនុញ្ញាតឱ្យកម្ពុជាអាចនាំទំនិញចូលទីផ្សារពិភពលោកក្នុងអត្រាពន្ធគយទាប ( MFN Rate ) ទៅកាន់ប្រទេសសមាជិក WTO ទាំងអស់ព្រមទាំងទទួលបានភាពអនុគ្រោះពន្ធផ្សេងៗទៀតក្នុងនាមជាប្រទេសអភិវឌ្ឍន៍តិចតួច ( LDC )។

ជាមួយគ្នានេះដែរ កម្ពុជាក៏បានចូលរួមចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីថ្នាក់តំបន់ជាមួយប្រទេសដៃគូសន្ទនារបស់អាស៊ានមួយចំនួន ដូចខាងក្រោម៖

### ២០០៤

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ( ACFTA )៖ ចុះហត្ថលេខាកាលពីឆ្នាំ២០០៤ និងចាប់ផ្តើមអនុវត្តកាលពីខែកក្កដា ឆ្នាំ២០០៥ ដោយកាត់បន្ថយពន្ធគយលើសពី ៧ ០០០ បន្ទាត់ពន្ធ ឬ ៩០% នៃការនាំចូលទៅ “សូន្យ” ត្រឹមឆ្នាំ២០១០ លើកលែងប្រទេស CLMV ត្រឹមឆ្នាំ២០១៥

### ២០០៧

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-សាធារណរដ្ឋកូរ៉េ ( AKFTA )៖ ចូលជាធរមានកាលពីឆ្នាំ២០០៧ ដោយកាត់បន្ថយពន្ធគយក្នុងរង្វង់ ៩០%

### ២០០៨

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ជប៉ុន ( AJFTA )៖ ចូលជាធរមានកាលពីខែធ្នូ ឆ្នាំ២០០៨ ដោយកាត់បន្ថយពន្ធគយសូន្យក្នុងរង្វង់៨៧%

### ២០១០

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ ( AANZFTA ) ៖ ចូលជាធរមានកាលពីខែមករា ឆ្នាំ២០១០ ដោយកាត់បន្ថយពន្ធគយសូន្យ ក្នុងរង្វង់ ៩០%

### ២០១០

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា ( AIFTA )៖ ចូលជាធរមានកាលពីខែមករា ឆ្នាំ២០១០ ដោយកាត់បន្ថយពន្ធគយសូន្យក្នុងរង្វង់ ៩០%

### ២០១៩

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន ( AHKFTA )៖ ចូលជាធរមានកាលពីខែមិថុនា ឆ្នាំ២០១៩ ដោយហុងកុងនឹងកាត់បន្ថយពន្ធគយ ១00%

ព័ត៌មានលម្អិតទាក់ទងនឹងកិច្ចព្រមព្រៀងខាងលើ អាចស្វែងរកបានតំណភ្ជាប់ខាងក្រោម៖
https://asean.org/free-trade-agreements-with-dialogue-partners/

ក្រៅពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជាក៏ទទួលបានភាពអនុគ្រោះពន្ធពីសហភាពអឺរ៉ុប ( EU EBA ) សហរដ្ឋអាមេរិក (US GSP) ចក្រភពអង់គ្លេស ( UK GSP )។ ក្នុងន័យនេះ កម្ពុជាអាចនាំចេញទំនិញស្ទើរតែគ្រប់ប្រភេទទៅកាន់ទីផ្សារទាំងនោះ ដោយមិនយកពន្ធនាំចូល និងកម្រិតកូតាទេ។



## ២.២ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី

### ២.២.១ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-ចិន (CCFTA)

បានប្រកាសបញ្ចប់ការចរចាជាផ្លូវការនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ និងត្រូវបានចុះហត្ថលេខា នាថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ តាមប្រព័ន្ធវីដេអូ

និងចូលជាធរមាននៅថ្ងៃទី១ ខែមករា ឆ្នាំ២០២២។

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន ត្រូវបានធ្វើឡើងក្នុងគោលបំណង៖

- ធ្វើការកាត់បន្ថយនិងលុបបំបាត់ពន្ធគយនិងរបាំងមិនមែនពន្ធគយដោយធានាថាស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃអនុលោមភាពមិនបង្កជាឧបសគ្គដល់ការធ្វើពាណិជ្ជកម្ម
- ធ្វើសេរីភាវូបនីយកម្ម និងសម្រួលពាណិជ្ជកម្មសេវាកម្មឱ្យបានច្រើនវិស័យនិងបែបបទនៃការផ្គត់ផ្គង់សេវា សម្រួលការពារជំរុញនិងទាក់ទាញវិនិយោគ
- ធ្វើពិពិធកម្មនិងលើកកម្ពស់ការតភ្ជាប់សេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគរវាងភាគីទាំងពីរ
- ពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងប្រទេសទាំងពីរ ស្របតាមគំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវនិង
- បង្កើតរចនាសម្ព័ន្ធសម្រាប់អនុវត្តកិច្ចព្រមព្រៀង និងកំណត់យន្តការដោះស្រាយវិវាទ។




កម្ពុជាទទួលបានការបញ្ចុះពន្ធគយពីភាគីចិន ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| អត្រាពន្ធអនុវត្ត 0% ភ្លាមៗ មានចំនួន ៨ ៣២៨ (មុខទំនិញ) បន្ទាត់ពន្ធ ស្មើនឹង ៩៧,៤៤% នៃបន្ទាត់ពន្ធសរុប | អត្រាពន្ធអនុវត្ត 0% ក្នុងរយៈពេល ០៥ឆ្នាំ មានចំនួន ០៦ (មុខទំនិញ) បន្ទាត់ពន្ធ ស្មើនឹង 0,0៧% នៃបន្ទាត់ពន្ធសរុប | អត្រាពន្ធអនុវត្ត 0% ក្នុងរយៈពេល ២០ឆ្នាំ មានចំនួន ០២ (មុខទំនិញ) បន្ទាត់ពន្ធ ស្មើនឹង 0,0២% នៃបន្ទាត់ពន្ធសរុប | អត្រាពន្ធអនុវត្ត ៥% មានចំនួន ៣០ (មុខទំនិញ) បន្ទាត់ពន្ធ ស្មើនឹងប្រមាណ 0,៣៥% នៃបន្ទាត់ពន្ធសរុប |

សរុបមុខទំនិញដែលកម្ពុជាទទួលបានការបញ្ចុះពន្ធគយទៅ 0% មាន ៨ ៣៣៦ បន្ទាត់ពន្ធគយ ស្មើនឹងប្រមាណ ៩៧,៥៣% នៃបន្ទាត់ពន្ធគយសរុប ដែលរួមមានប្រភេទទំនិញដូចខាងក្រោម៖



**កសិកម្ម៖**
បន្លែ ផ្លែឈើ គ្រាប់ធញ្ញជាតិផ្សេងៗ គ្រាប់ និងផ្លែធញ្ញជាតិផ្សេងៗ សត្វរស់ សាច់សត្វ ត្រី ពពួកសត្វរស់នៅក្នុងទឹក ផលិតផលទឹកដោះ សត្វស្លាប ទឹកឃ្មុំ។



**កសិកម្មកែច្នៃ៖**
ដំណាំឧស្សាហកម្មនានា ជ័រ និងជ័រចម្រាញ់ពីរុក្ខជាតិផ្សេងៗ ខ្លាញ់សត្វ និងប្រេងរុក្ខជាតិនានា គ្រឿងបរិភោគដែលកែច្នៃរួច ភេសជ្ជៈ វត្ថុដែលមានជាតិស្រវឹង ទឹកខ្មេះ លើកលែងស្ករស និងថ្នាំជក់។ល។



**ឧស្សាហកម្ម៖**
ផលិតផលរ៉ែ ក្រោមផលិតផលនៃឧស្សាហកម្មគីមី ឬផលិតផលឧស្សាហកម្មជាសម្ព័ន្ធ ឱសថ សារធាតុផ្សេងៗ និងប្លាស្ទិក ផលិតផលធ្វើពីប្លាស្ទិកជាដើម។

ព័ត៌មានបន្ថែមទាក់ទងនឹងកិច្ចព្រមព្រៀងខាងលើនេះ អាចស្វែងរកបានតំណភ្ជាប់ខាងក្រោម៖
https://www.moc.gov.kh/official-documents?category_id=6

### ២.២.២ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-កូរ៉េ (CKFTA)

ចាប់ផ្តើមចរចាកាលពីខែកក្កដា ឆ្នាំ២០២០ និងត្រូវបានចុះហត្ថលេខានៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១

កម្ពុជាបានផ្តល់សច្ចាប័នកាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២។

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ ត្រូវបានធ្វើឡើងក្នុងគោលបំណង ដើម្បី៖

- ធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម រវាងគូភាគីដោយអនុលោមតាមច្បាប់ពាណិជ្ជកម្មអន្តរជាតិ
- ជំរុញការប្រកួតប្រជែងរវាងគូភាគី ជាពិសេសការប្រកួតប្រជែងដែលពាក់ព័ន្ធនឹងទំនាក់ទំនងសេដ្ឋកិច្ច
- លើកកម្ពស់តម្លាភាពនៃវិធានការពាណិជ្ជកម្មនិងវិនិយោគរបស់គូភាគី តាមរយៈការចែករំលែកនូវឧត្តមានុវត្តន៍ និយ័តកម្ម និងការជំរុញនវានុវត្តន៍ក្នុងវិស័យដែលមានផលប្រយោជន៍ទៅវិញទៅមកបង្កើតក្របខ័ណ្ឌ
- សម្រាប់ជំរុញបន្ថែមនូវកិច្ចសហប្រតិបត្តិការ សំដៅពង្រីកនិងលើកកម្ពស់សារប្រយោជន៍នៃកិច្ចព្រមព្រៀងនេះ
- ជំរុញការនាំចេញ និងបង្កើនទំហំផលិតកម្មទំនិញ
- ជំរុញកំណើនសេដ្ឋកិច្ចជាតិ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

- ការផ្តល់ទីផ្សាររបស់ភាគីកូរ៉េឱ្យមកកម្ពុជា ក្រោមកិច្ចព្រមព្រៀង CKFTA មានចំនួន ៩៥,០៣% នៃបន្ទាត់ពន្ធគយសរុប ដែលក្នុងនោះភាគីកូរ៉េត្រូវលុបបំបាត់ពន្ធគយ (0%) ចំនួន ៩២,៣៧% ភ្លាមនៅពេលកិច្ចព្រមព្រៀងចូលជាធរមាន។



### បើធៀបនឹងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលភាគីទាំងពីរជាសមាជិក កម្ពុជាទទួលបានទីផ្សារបន្ថែម៖

៤,៣៥% ស្មើនឹង ៥៣៣ បន្ទាត់ពន្ធគយ ខ្ពស់ជាងក្របខ័ណ្ឌអាសិប (RCEP) (៩០,៦៨%)

៥,០៥% ស្មើនឹង ៦១៨ បន្ទាត់ពន្ធគយខ្ពស់ជាងក្របខ័ណ្ឌអាស៊ាន-កូរ៉េ (AKFTA) (៨៩,៩៨%)



៥,១៣% ស្មើនឹង ៦២៨ បន្ទាត់ពន្ធគយ ខ្ពស់ជាង GSP ក្រោមក្របខ័ណ្ឌអង្គការ WTO (៨៩,៩០%) សម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច (LDCs)។

កិច្ចព្រមព្រៀងនេះ នឹងលើកកម្ពស់ការនាំចេញរបស់កម្ពុជាទៅកាន់សាធារណរដ្ឋកូរ៉េបន្ថែមទៀត លើទំនិញដែលធ្លាប់នាំចេញកន្លងមក និងមុខទំនិញយុទ្ធសាស្ត្រសំខាន់ៗរបស់កម្ពុជាដទៃទៀតក្នុងអត្រាពន្ធ0% ដែលរួមមាន៖



**ទំនិញឧស្សាហកម្ម**

កង់ ជ័រកៅស៊ូ គ្រឿងបង្គុំអេឡិចត្រូនិក គ្រឿងសង្ហារឹម នំក្រៀម ស្ករស ស្ករអំពៅ កាបូបយួរដៃ វ៉ាលី ខ្សែភ្លើង ខ្សែកាបអេឡិចត្រូនិកអគ្គិសនី សម្ភារកីឡា របស់តុបតែងធ្វើពីវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងគ្រឿងបង្គុំកុំព្យូទ័រ



**ទំនិញកសិកម្ម**

ម្រេច គ្រាប់ស្វាយចន្ទី ចេកអំបូងលឿង ដំឡូង ផ្សិត មង្ឃុត ដូង ម្នាស់ ឪឡឹក ធូរេន ត្របែក រមៀត ពោត ថ្នាំជក់ គ្រាប់កាហ្វេ ប្រភេទសាច់ និងវារីវប្បកម្មមួយចំនួន



**ទំនិញអាហារកែច្នៃ**

លើសពីនេះ កម្ពុជាទទួលបានទីផ្សារអត្រាពន្ធ 0% លើទំនិញអាហារកែច្នៃពីអង្ករ(គុយទាវ នំក្រៀម និងនំស្រួយផលិតពីអង្ករ) និងប្រភេទទំនិញកសិកម្មកែច្នៃ (សំបុកត្រចៀកកាំ ទំនិញកែច្នៃពីត្រី ផ្លែមៀន ទំនិញកែច្នៃពីដូង ជាដើម)។

## ៣. កម្ពុជា និងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (អាសិប)

### ៣.១ ទិដ្ឋភាពទូទៅ និងលក្ខណៈពិសេសនៃកិច្ចព្រមព្រៀងអាសិប

អាសិបជាកិច្ចព្រមពៀងពាណិជ្ជកម្មសេរីធំបំផុតលើពិភពលោកដែលមានសមាជិកចំនួន១៥ប្រទេស រួមមានប្រទេសសមាជិកអាស៊ានទាំង១០ និងប្រទេសដៃគូពាណិជ្ជកម្មអាស៊ានចំនួន០៥ ដូចជា អូស្ត្រាលី ចិន ជប៉ុន កូរ៉េខាងត្បូង និងនូវែលសេឡង់ ត្រូវបានប្រកាសឱ្យចាប់ផ្តើមចរចាកាលពីឆ្នាំ២០១២ នៅរាជធានីភ្នំពេញ ដែលកម្ពុជាជាប្រធានអាស៊ានឆ្លាស់វេន ដែលត្រូវបានចុះហត្ថលេខាកាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២០ និងបានចូលជាធរមានកាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២២។







បង្កើតបានទីផ្សារ ២,២ ពាន់លាននាក់ នៃចំនួនប្រជាជនពិភពលោក




មានផលិតផលក្នុងស្រុកសរុបរួមគ្នាប្រមាណ ២៦,២ ទ្រីលានដុល្លារអាម៉េរិក




ទំហំពាណិជ្ជកម្មពិភពលោក

## ● អត្ថប្រយោជន៍សំខាន់ៗ៤ចំណុចនៃកិច្ចព្រមព្រៀងអាសិប



### ទំនើប៖

កិច្ចព្រមព្រៀងអាសិបជំរុញការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក សក្តានុពលរបស់សហគ្រាសធុនតូច និងមធ្យម ការធ្វើឱ្យស៊ីជម្រៅនៃខ្សែច្រវាក់តម្លៃតំបន់និងការប្រកួតប្រជែងទីផ្សារ។



### គ្រប់ជ្រុងជ្រោយ៖

កិច្ចព្រមព្រៀងអាសិបមាន២០ជំពូក និងមានបញ្ចូលវិស័យជាច្រើនទៀតដែលមិនធ្លាប់មាននៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានបូកមួយពីមុន រួមមាន ពាណិជ្ជកម្មទំនិញ វិធានដើមកំណើតទំនិញ នីតិវិធីគយនិងកិច្ចសម្រួលពាណិជ្ជកម្ម វិធានការអនាម័យនិងភូតគាមអនាម័យ ស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃអនុលោមភាព និងឧបាស្រ័យពាណិជ្ជកម្ម។



### គុណភាពខ្ពស់៖

កិច្ចព្រមព្រៀងអាសិបក៏បានរំលេចនូវបញ្ហាប្រឈមនានាដើម្បីគាំទ្រដល់ការចូលរួមរបស់សមាជិកនីមួយៗ នៅក្នុងខ្សែច្រវាក់តម្លៃសកលនិងតំបន់ និងបំពេញនូវការបើកទីផ្សារជាមួយនឹងគោលការណ៍លើកទឹកចិត្តពាណិជ្ជកម្មនិងវិនិយោគ ដែលមានលក្ខណៈលើកកម្ពស់ការធ្វើអាជីវកម្មនិងប្រកាន់ភ្ជាប់នូវគោលបំណងគោលនយោបាយសាធារណៈស្របច្បាប់។



### ផ្តល់អត្ថប្រយោជន៍ឱ្យគ្នាទៅវិញទៅមក៖

កិច្ចព្រមព្រៀងអាសិបបានប្រមូលផ្តុំប្រទេសដែលមានស្ថានភាពផ្សេងៗគ្នា។ ដូចនេះ សមាជិកអាសិបបានទទួលស្គាល់ថាភាពជោគជ័យរបស់កិច្ចព្រមព្រៀងនេះ នឹងត្រូវកំណត់ដោយសមត្ថភាពក្នុងការផ្តល់ផលប្រយោជន៍ដល់សមាជិកទាំងអស់។

## ៣.២ បច្ច័យសក្តានុពលរបស់កិច្ចព្រមព្រៀងអាសិបមកលើសេដ្ឋកិច្ចកម្ពុជា

ផ្អែកតាមលទ្ធផលសិក្សារបស់វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីបូព៌ា (ERIA) បានបង្ហាញថា បន្ទាប់ពីបញ្ចប់កិច្ចព្រមព្រៀងអាសិបនេះ កម្ពុជាអាចនឹងមានកំណើនប្រចាំឆ្នាំការនាំចេញចំនួន ៧,៣% វិនិយោគចំនួន ២៣,៤% និងផលិតផលក្នុងស្រុកសរុបចំនួនប្រមាណ ២% លើផលិតផលក្នុងស្រុកសរុបដែលមានបច្ចុប្បន្ន។

ជាមួយគ្នានេះដែរ តាមការសិក្សារួមគ្នារបស់អ្នកជំនាញនៃវិទ្យាស្ថាន ERIA ជាមួយក្រុមការងារស្រាវជ្រាវរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ដែលបានបោះពុម្ពផ្សាយនាពេលថ្មីៗនេះ បានបង្ហាញថាកម្ពុជាអាចនឹងមានកំណើនប្រចាំឆ្នាំការនាំចេញក្នុងរង្វង់ប្រមាណពី៩,៤%ទៅ១៨%ដែលនឹងចូលរួមចំណែកក្នុង៖

| ២%-៣,៩% | ៣,២%-៦,២% | ២%-៣,៨% |
|---|---|---|
| រំពឹងកើនលើចំណូលពន្ធ | រំពឹងនឹងកើនលើ ចំនួនការងារ | រំពឹងនឹងកើនលើ កំណើនសេដ្ឋកិច្ច |

**ប្រភព៖** Regional Comprehensive Economic Partnership; Implications, Challenges, and Future Growth of East Asia and ASEAN (2022)

កម្ពុជាទទួលបានភាពអនុគ្រោះពន្ធពីកិច្ចព្រមព្រៀងនេះលើទំនិញសំខាន់ៗជាច្រើនរួមមាន៖



| | |
|---|---|
| **ទំនិញកសិកម្ម៖** | គ្រាប់ស្វាយចន្ទី ពោត ដូង ស្វាយស្រស់ ចេក ដំឡូងជ្វា ទឹកឃ្មុំ ម្សៅមៀត ក្រូច ល្ហុង។ល។ |
| **កសិកម្មកែច្នៃ៖** | គុយទាវ នំក្រៀម សំបុកត្រចៀកកាំ ទំនិញកែច្នៃពីត្រី ម្សៅដំឡូងមី ទំនិញកែច្នៃពីដូងប្រេង សណ្តែកដី សាច់ក្រក ទឹកម្ទេស ដំណាប់។ល។ |
| **ឧស្សាហកម្ម៖** | កង់ សម្លៀកបំពាក់ ស្បែកជើង គ្រឿងបង្គុំអេឡិចត្រូនិក ខ្សែកាបអេឡិចត្រូនិកអគ្គិសនី គ្រឿងសង្ហារឹម ស្គរស ស្ករអំពៅ កាបូបយួរដៃ។ល។ |

## ៣.៣ ចំណុចសំខាន់ៗនៃជំពូកសំខាន់ៗរបស់កិច្ចព្រមព្រៀងអាស៊ាន

### ៣.៣.១ ពាណិជ្ជកម្មទំនិញ

ក្នុងជំពូកនេះ បានបញ្ចូលនូវធាតុសំខាន់ៗ ដែលគ្រប់គ្រងការអនុវត្តការសន្យាទាក់ទងនឹងពាណិជ្ជកម្មទំនិញដើម្បីសម្រេចបាននូវកម្រិតសេរីភាវូបនីយកម្មពាណិជ្ជកម្មក្នុងតំបន់ពាណិជ្ជកម្មសេរី។ ទាំងនេះរួមបញ្ចូល៖




ជំពូកនេះ ក៏រួមបញ្ចូលផងដែរនូវបទប្បញ្ញត្តិស្តីពីការអនុវត្តខុសគ្នានៃការកំណត់ពន្ធគយ មិនត្រឹមតែដើម្បីរារាំងការជៀសវាងនោះទេ ប៉ុន្តែសំខាន់ជាងនេះទៀតដើម្បីធានាថារាល់ទំនិញដែលមានប្រភពដើមត្រូវបានអនុគ្រោះពន្ធគយ និងអនុគ្រោះពន្ធគយសមស្រប ត្រូវបានផ្តល់ជូនតែចំពោះប្រទេសជាសមាជិកដែលជាកន្លែងទំនិញផលិតចុងក្រោយ។

### កម្រិតសេរីភាវូបនីយកម្មជាមួយប្រទេសដៃគូពាណិជ្ជកម្មសេរីអាស៊ាន (AFPs)

| AFPs | ចំនួននៃបន្ទាត់ពន្ធ (មុខទំនិញ) | ចំនួនភាគរយ |
|---|---|---|
| អូស្ត្រាលី | ៥ ៦៨៩ | ៩២,០០% |
| ចិន | ៧ ៤៩១ | ៩០,៥០% |
| កូរ៉េ | ១១ ០៩៦ | ៩០,៦៣% |
| ជប៉ុន | ៨ ១៣៨ | ៨៩,៥២% |
| នូវែលសេឡង់ | ៦ ៨៦៣ | ៩១,៨១% |

### ៣.៣.២ វិធានដើមកំណើតទំនិញ

ជំពូកនេះ បានដាក់ចេញនូវគោលការណ៍ណែនាំ ដើម្បីកំណត់និងបញ្ជាក់ប្រភពដើមទំនិញដើម្បីទទួលបានការអនុគ្រោះពន្ធ។




ជំពូកនេះក៏បានកំណត់នូវបញ្ជីប្រតិបត្តិការនិងដំណើរការដែលមានលក្ខណៈតិចតួចបំផុតឬដំណើរការទាំងឡាយណាដែលត្រូវបានចាត់ទុកថាមិនគ្រប់គ្រាន់ដើម្បីទទួលបានប្រភពដើមទំនិញ ដោយប្រើប្រាស់វត្ថុធាតុដើមពីប្រទេសដែលមិនមែនជាសមាជិកអាស៊ាន។

វិធានដើមកំណើតទំនិញក្នុងកិច្ចព្រមព្រៀងអាស៊ាន រួមមានការបញ្ចូលនូវភ័ស្តុតាងផ្សេងទៀត ដែលបញ្ជាក់ពីប្រភពដើម ដូចជាការប្រកាសប្រភពដើមដោយអ្នកនាំចេញ ឬការប្រកាសប្រភពដើមដោយអ្នកនាំចេញឬអ្នកផលិតបន្ថែមលើវិញ្ញាបនបត្របញ្ជាក់ប្រភពដើម។ កិច្ចព្រមព្រៀងអាស៊ាន គឺអាចប្រើប្រាស់វត្ថុធាតុដើមពីភាគីផ្សេងទៀតដើម្បីផលិតជាទំនិញ។

# ជំពូកវិធានដើមកំណើតទំនិញ មានឧបសម្ព័ន្ធពីរ៖

១




វិធានជាក់លាក់សម្រាប់ផលិតផលដែលគ្របដណ្តប់លើតារាងពន្ធគយចំនួន ៥ ២០៥ បន្ទាត់ពន្ធ នៅកម្រិត HS ៦ខ្ទង់។

២



នីតិវិធីសម្រាប់ផ្តល់វិញ្ញាបនបត្រប្រតិបត្តិការ ដែលផ្តល់នូវនីតិវិធីលម្អិតសម្រាប់ការដាក់ពាក្យសុំភ័ស្តុតាងដែលបញ្ជាក់ពីប្រភពដើមអាសិប ការស្នើសុំអនុគ្រោះពន្ធ និងការផ្ទៀងផ្ទាត់ប្រភពដើមទំនិញ។

## វិធានដើមកំណើតទំនិញគឺជាអ្វី? ហេតុអ្វីត្រូវការវិធាននេះ?




វិធានដើមកំណើតទំនិញ គឺជាវិធានដែលគេប្រើសម្រាប់កំណត់ដើមកំណើតទំនិញរបស់ប្រទេសមួយ។ ក្នុងបរិបទនៃកិច្ចព្រមព្រៀងអាសិប គេប្រើវិធានដើមកំណើតនេះ ដើម្បីកំណត់ដើមកំណើតទំនិញ ឬផលិតផលរបស់ប្រទេសជាសមាជិក ដើម្បីទទួលបានការអនុគ្រោះពន្ធ ពេលនាំចូលទៅទីផ្សារអាសិប។




នៅពេលទំនិញ ឬផលិតផល អាចគោរពបាន និងអនុលោម តាមវិធានដើមកំណើតទំនិញរបស់អាសិប នោះអាជ្ញាធរចេញវិញ្ញាបនបត្រនៃប្រទេសសមាជិកនឹងចេញវិញ្ញាបនបត្រ បញ្ជាក់ដើមកំណើតទំនិញ ទម្រង់អាសិប (CO Form RCEP) ជូន។

## អត្ថប្រយោជន៍ នៃវិធានដើមកំណើតទំនិញក្រោមអាសិប

ប្រើប្រាស់វិធានដើមកំណើតទំនិញរួម ដើម្បីនាំចេញទំនិញ ទទួលបានការអនុគ្រោះពន្ធទៅទីផ្សារអាសិប




វិធានដើមកំណើតទំនិញក្រោមអាសិប មានភាពសាមញ្ញ និងងាយស្រួលបំពេញបាន ជាងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីមួយចំនួនទៀតាមផលិតផល ដែលកម្ពុជាជាសមាជិក

វិធានបូកបន្ថែម អាចជួយឱ្យកម្ពុជាអាចនាំចូលវត្ថុធាតុដើមពីប្រទេសសមាជិក កែច្នៃរួចនាំចេញទៅទីផ្សារអាសិបវិញ ងាយនឹងបំពេញបាននូវវិធានដើមកំណើតទំនិញ

## ៣.៣.៣ នីតិវិធីគយ និងកិច្ចសម្រួលពាណិជ្ជកម្ម

គោលដៅនៃជំពូកនេះ គឺដើម្បី៖



០១ ធានាឱ្យបាននូវភាពអាចព្យាករណ៍បាន សង្គតិភាព និងតម្លាភាពក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិគយនានារបស់ភាគីសមាជិកនីមួយៗ

០២ លើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងអនុវត្តនីតិវិធីគយរបស់ភាគីសមាជិកនីមួយៗ និងការបញ្ចេញទំនិញពីគយបានរហ័ស

០៣ សម្រួលនីតិវិធីគយរបស់ភាគីសមាជិកនីមួយៗ និងធ្វើឱ្យមានសុខដុមនីយកម្ម តាមលទ្ធភាពដែលអាចធ្វើទៅបាន អនុលោមតាមបទដ្ឋានអន្តរជាតិពាក់ព័ន្ធ

០៤ លើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរគយរបស់ភាគីសមាជិក និង

០៥ សម្រួលពាណិជ្ជកម្មរវាងភាគីសមាជិក រួមមានតាមរយៈការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសសម្រាប់ខ្សែច្រវាក់ផ្គត់ផ្គង់សកល និងតំបន់។

## លក្ខណៈពិសេសនៃនីតិវិធីគយ និងកិច្ចសម្រួលពាណិជ្ជកម្ម ក្រោមក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងអាស៊ាន៖

- ការចេញវិធានបញ្ជាក់ជាមុន HS, ROO, CV ក្នុងអំឡុងពេលកំណត់ ៩០ថ្ងៃ
- រយៈពេល៤៨ម៉ោងសម្រាប់បញ្ចេញទំនិញ និងរយៈពេល ៦ម៉ោង ដើម្បីបញ្ចេញទំនិញងាយខូចគុណភាពពីគយ
- ផ្តល់ជូនប្រតិបត្តិករនូវវិធានការសម្រួលពាណិជ្ជកម្មបន្ថែម ដើម្បីបំពេញលក្ខខណ្ឌជាប្រតិបត្តិករទទួលបានការអនុញ្ញាត
- ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីគាំទ្រកិច្ចដំណើរការការងារគយតាមដែលអាចធ្វើទៅបាន សម្រាប់ការបំពេញបែបបទ និងការបញ្ចេញទំនិញរហ័ស
- អនុវត្តអភិក្រមនៃការគ្រប់គ្រងហានិភ័យ ដើម្បីត្រួតពិនិត្យគយនិងសវនកម្ម ក្រោយពេលបញ្ចេញទំនិញពីគយ។

## ៣.៣.៤ វិធានការអនាម័យ និងភូតគាមអនាម័យ

ជំពូកនេះ បានដាក់ចេញនូវក្របខ័ណ្ឌមូលដ្ឋានសម្រាប់ការរៀបចំអនុម័ត និងអនុវត្តវិធានការអនាម័យនិងភូតគាមអនាម័យ សម្រាប់គោលបំណងធានាសុវត្ថិភាពចំណីអាហារ និងការពារជីវិតមនុស្ស សត្វ ឬរុក្ខជាតិ ឬសុខភាព។

ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃជំពូកវិធានការអនាម័យនិងភូតគាមអនាម័យនឹងធានាថា វិធានការអនាម័យ និងភូតគាមអនាម័យ ត្រូវបានអនុវត្តតែក្នុងកម្រិតចាំបាច់បំផុត ដើម្បីការពារសុខភាព រឹតត្បិតពាណិជ្ជកម្មតិចតួចបំផុតតាមដែលអាចធ្វើទៅបាន ហើយមិនគួររើសអើងរវាងភាគីណាមួយ ដែលមានលក្ខខណ្ឌស្រដៀងគ្នានោះទេ។

ខណៈពេលដែលភាគីអាស៊ានបញ្ជាក់ពីសិទ្ធិ និងកាតព្វកិច្ចរបស់ពួកគេ ក្រោមកិច្ចព្រមព្រៀងស្តីពីអនាម័យ និងភូតគាមអនាម័យរបស់អង្គការពាណិជ្ជកម្មពិភពលោក បទប្បញ្ញត្តិជាក់លាក់មួយចំនួនត្រូវបានឯកភាព ដើម្បីលើកកម្ពស់ការអនុវត្តកិច្ចព្រមព្រៀងពហុភាគី។




## ៣.៣.៥ ស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃអនុលោមភាព

### គោលដៅនៃជំពូកនេះ គឺដើម្បីសម្រួលដល់ការធ្វើពាណិជ្ជកម្មទំនិញក្នុងចំណោមភាគីសមាជិក ដោយៈ



- លើកកម្ពស់ការអនុវត្តកិច្ចព្រមព្រៀងស្តីពី របាំងបច្ចេកទេសពាណិជ្ជកម្ម
- ពង្រឹងនូវការផ្លាស់ប្តូរព័ត៌មាន និងកិច្ចសហប្រតិបត្តិការក្នុងចំណោមភាគីសមាជិក នៅក្នុងវិស័យស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេសនិងនីតិវិធីវាយតម្លៃអនុលោមភាព រួមបញ្ចូលទាំងការងាររបស់អង្គភាពអន្តរជាតិពាក់ព័ន្ធ
- បង្កើតឱ្យមាននូវក្របខ័ណ្ឌការងារដើម្បីសម្រេចបាននូវគោលដៅទាំងនេះ។
- ធានាថា ស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃអនុលោមភាព មិនបង្កើតជាឧបសគ្គ មិនចាំបាច់ចំពោះពាណិជ្ជកម្ម
- ជំរុញការយោគយល់គ្នាទៅវិញទៅមកនូវស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃអនុលោមភាពរបស់ភាគីសមាជិកនីមួយៗ
- ដោះស្រាយបញ្ហាដែលអាចកើតមាននៅក្រោមជំពូកនេះ

### គោលបំណងទាំងនេះនឹងត្រូវបានសម្រេចតាមរយៈបទប្បញ្ញត្តិ៖

គោលបំណងទាំងនេះនឹងត្រូវបានសម្រេចតាមរយៈបទប្បញ្ញត្តិ

១ ទទួលស្គាល់តួនាទីសំខាន់នៃស្តង់ដារ ការណែនាំ និងយោបល់អន្តរជាតិ អាចដើរតួជាឯកសារយោងសំខាន់ក្នុងការធ្វើឱ្យមានសង្គតិភាព ដើម្បីកាត់បន្ថយរបាំងបច្ចេកទេសដែលមិនចាំបាច់សម្រាប់ការធ្វើពាណិជ្ជកម្ម។

២ ធានាថាស្ថាប័នដែលមានលក្ខណៈស្តង់ដារដែលទទួលខុសត្រូវក្នុងការរៀបចំនិងអនុវត្តស្តង់ដារជាតិ បទប្បញ្ញត្តិបច្ចេកទេសនិងនីតិវិធីវាយតម្លៃអនុលោមភាព ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធនៃកិច្ចព្រមព្រៀងរបាំងបច្ចេកទេសពាណិជ្ជកម្ម។

## អត្ថប្រយោជន៍សម្រាប់ក្រុមហ៊ុននាំចេញ



១) ការដកចេញនូវការធ្វើតេស្តស្ទួនៗ ការធ្វើអធិការកិច្ច ត្រួតពិនិត្យ និងការបញ្ជាក់ទំនិញនៅក្នុងប្រទេសគោលដៅ និងថ្លៃដើមពាក់ព័ន្ធនានា





២) កាត់បន្ថយថ្លៃដើមភ័ស្តុភារ ដែលមិនតម្រូវឱ្យដឹកជញ្ជូនផលិតផលត្រឡប់ទៅប្រទេសដើមវិញ ក្នុងករណីដែលគយក្នុងប្រទេសគោលដៅបដិសេធទំនិញ



៣) កាត់បន្ថយពេលវេលាដែលត្រូវការដើម្បីចូលទៅកាន់ទីផ្សារបរទេស ដោយសារកង្វះការធ្វើតេស្តស្ទួន ឬតម្រូវការបន្ថែម។

## ៣.៣.៦ ឧបាស្រ័យពាណិជ្ជកម្ម

ជំពូកនេះ មានពីរផ្នែក៖





### ១| វិធានការការពារ

អនុញ្ញាតឱ្យភាគីនីមួយៗប្រើប្រាស់យន្តការ ដើម្បីដោះស្រាយខាតបង់ ឬការគំរាមកំហែងការខាតបង់ដល់ឧស្សាហកម្មក្នុងស្រុក ដែលបណ្ដាលមកពីការប្ដេជ្ញាចិត្តរបស់ភាគីនីមួយៗក្រោមកិច្ចព្រមព្រៀងអាសិប។

### ២| ផ្នែកការប្រឆាំងការលក់បង្ខូចថ្លៃ និងវិធានការពន្ធប៉ះប៉ូវ

បញ្ជាក់ជាថ្មី និងរៀបចំឡើងផ្នែកលើសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនីមួយៗ ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងពាក់ព័ន្ធនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក។ ផ្នែកនេះក៏រួមបញ្ចូលផងដែរនូវការអនុវត្តការប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងវិធានការប៉ះប៉ូវរបស់ភាគីអាសិបមួយចំនួនដែលអាចលើកកម្ពស់គោលដៅនៃតម្លាភាពនិងនីតិវិធីត្រឹមត្រូវក្នុងនីតិវិធីដោះស្រាយសំណងពាណិជ្ជកម្ម។

## ហេតុអ្វីចាំបាច់មានជំពូកស្ដីពីឧបាស្រ័យពាណិជ្ជកម្ម ក្នុងកិច្ចព្រមព្រៀងអាសិប?

- ខែលការពារសម្រាប់ឧស្សាហកម្មក្នុងស្រុក
- សេរីភាវូបនីយកម្មពាណិជ្ជកម្ម តាមរយៈការកាត់បន្ថយ ឬលុបបំបាត់ពន្ធគយក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី




មានការប្រកួតប្រជែង "លើសលប់" ដោយសារបរិមាណនាំចូលកើនឡើងយ៉ាងគំហុក

អាចបង្កឬគំរាមកំហែងឱ្យមានការខូចខាតធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុក

សមាសធាតុសំខាន់ៗនៃវិធានការការពារក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាសិប

វិធានការការពារប្រើបាននៅពេលណា?



បរិមាណនាំចូលពីប្រទេសសមាជិកអាសិបកើនឡើងយ៉ាងគំហុក




បង្ក ឬគំរាមកំហែងឱ្យមានការខូចខាតធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុកដែលផលិតនូវផលិតផលដូចគ្នា

### ទម្រង់នៃវិធានការការពារ



## រយៈពេលនៃវិធានការការពារ

មិនលើស

**៣** ឆ្នាំ (អាចបន្តបាន ១ ឆ្នាំទៀត)

## យន្តការដោះស្រាយវិវាទ

អាចស្នើសុំដោះស្រាយវិវាទក្រោមវេទិកាដែលមានចែងក្រោមយន្តការរបស់កិច្ចព្រមព្រៀងបាន

## សមាសធាតុសំខាន់ៗនៃវិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងវិធានការពន្ធតបតក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន

### វិធានការការពារប្រើបាននៅពេលណា?

០១ មានការលក់បង្ខូចថ្លៃមានឧបត្ថម្ភធន



០៣ ផលិតនូវផលិតផលដូចគ្នា



០២ បង្កឬគំរាមកំហែងឱ្យមានការខូចខាតសម្ភារដល់ឧស្សាហកម្មក្នុងស្រុក ឬឧស្សាហកម្មក្នុងស្រុកលូតលាស់យឺត



## ទម្រង់នៃវិធានការការពារ

- វិធានការបណ្ដោះអាសន្ន (មិនលើស ៤-៦ខែ)
- ដំឡើងអត្រាពន្ធគយ កែសម្រួលថ្លៃ



## រយៈពេលនៃវិធានការការពារ

មិនលើស

**៥** ឆ្នាំ (អាចបន្តបានទៀត)



# ៣.៣.៧ ពាណិជ្ជកម្មសេវាកម្ម

ជំពូកនេះ បើកផ្លូវសម្រាប់ការធ្វើពាណិជ្ជកម្មសេវាឱ្យកាន់តែប្រសើរឡើងសម្រាប់បណ្ដាភាគីនៃកិច្ចព្រមព្រៀងអាស៊ាន តាមរយៈការកាត់បន្ថយភាពរឹតត្បិត និងវិធានការរើសអើងសម្រាប់ពាណិជ្ជកម្មឆ្លងកាត់ព្រំដែនក្នុងវិស័យសេវាកម្ម។

ជំពូកនេះ រួមមានបទប្បញ្ញត្តិបែបទំនើបនិងគ្រប់ជ្រុងជ្រោយស្ដីពីពាណិជ្ជកម្មសេវាកម្ម ដែលគ្របដណ្ដប់លើកាតព្វកិច្ចជាច្រើនរួមមាន៖




ជំពូកនេះ ក៏តម្រូវឱ្យភាគីអាស៊ានរៀបចំតារាង កំណត់ការសន្យាវិស័យសេវាកម្មរបស់ពួកគេ ដោយប្រើបញ្ជីអវិជ្ជមាននៅពេលដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន ឬប៉ុន្មានឆ្នាំបន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន។ តាមរយៈការប្រើប្រាស់បញ្ជីអវិជ្ជមាន ការសន្យាលើសេវាកម្មក្រោមកិច្ចព្រមព្រៀងអាស៊ាន ផ្ដល់នូវរូបភាពកាន់តែច្បាស់ចំពោះបទប្បញ្ញត្តិនានាមានស្រាប់ ដែលត្រូវបានអនុវត្តនៅក្នុងវិស័យនេះ និងផ្ដល់នូវភាពជាក់លាក់កាន់តែច្រើនឡើងសម្រាប់អ្នកផ្គត់ផ្គង់សេវាកម្មបរទេស។

## ក្នុងជំពូកនេះមានឧបសម្ព័ន្ធសំខាន់ៗចំនួន៣

១) ឧបសម្ព័ន្ធស្ដីពីសេវាកម្មហិរញ្ញវត្ថុ៖ គាំទ្រនូវវិធានបន្ថែមលើការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុ ហើយក៏គាំទ្រនូវគោលនយោបាយនិងលំហសម្រាប់ការពារប្រឆាំងនឹងអស្ថិរភាពនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ។

២) ឧបសម្ព័ន្ធស្ដីពីសេវាកម្មទូរគមនាគមន៍៖ ផ្ដល់ជូននូវក្របខ័ណ្ឌនៃច្បាប់ពាក់ព័ន្ធនឹងពាណិជ្ជកម្មសេវាកម្មទូរគមនាគមន៍ (១)វិធីសាស្ត្រនៃបទប្បញ្ញត្តិ (២)ប្រព័ន្ធខ្សែកាបក្រោមសមុទ្រអន្តរជាតិ (៣)ការមិនដាក់រួមនូវធាតុនៃបណ្ដាញ (៤)ការចូលប្រើប៉ូលបំពង់ និងទុយោ និងភាពបត់បែនក្នុងការប្រើប្រាស់បច្ចេកវិទ្យា និង(៥)ទូរស័ព្ទចល័តរ៉ូមមីងអន្តរជាតិ។



៣)ឧបសម្ព័ន្ធស្ដីពីសេវាកម្មវិជ្ជាជីវៈ៖ ផ្ដល់ផ្លូវសម្រាប់ភាគីនៃកិច្ចព្រមព្រៀងអាស៊ាន ដើម្បីកំណត់សេវាកម្មវិជ្ជាជីវៈដែលភាគីពីរ ឬច្រើនដែលមានចំណាប់អារម្មណ៍។

## ៣.៣.៨ វិនិយោគ

- ក្នុងជំពូកវិនិយោគមានគោលបំណងបង្កើតបរិយាកាសវិនិយោគប្រកបដោយភាពសេរីនៅក្នុងតំបន់។



- ជំពូកនេះ មានបទប្បញ្ញត្តិ ដែលលក្ខណប្រសើរជាងមុនគ្របដណ្តប់លើសសរស្តម្ភទាំងបួននៃការវិនិយោគនិងការការពារ សេរីភាវូបនីយកម្ម ការលើកកម្ពស់និងការសម្របសម្រួលលើអ្វីដែលមានស្រាប់នៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានដែលមាន។
- ជំពូកនេះ រួមបញ្ចូលទាំងប្រយោគពាក់ព័ន្ធនឹងប្រជាជាតិ ដែលមានការអនុគ្រោះបំផុត ហើយក៏មានចែងផងដែរនូវការហាមឃាត់នូវតម្រូវការលើការអនុវត្តបន្ថែមលើអ្វីដែលមានចែងក្នុងវិធានវិនិយោគ ក្រោមច្បាប់ពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក។
- ជំពូកនេះក៏មានឧបសម្ព័ន្ធ ស្តីពីបញ្ជីរក្សាទុកចំនួន២ ដែលមានយន្តការកំណត់នូវការសន្យាបើកទីផ្សារ និងការរក្សាទុករបស់បណ្តាភាគីយ៉ាងច្បាស់លាស់។
- ជំពូកនេះផ្តល់នូវការកែលម្អបទប្បញ្ញត្តិសម្របសម្រួលការវិនិយោគ ដែលយកចិត្តទុកដាក់លើអ្នកវិនិយោគ ដូចជាការដោះស្រាយបណ្តឹងតវ៉ា និងការតវ៉ាដែលអាចកើតមាន។

## ៣.៣.៩ កម្មសិទ្ធិបញ្ញា



គោលដៅនៃជំពូកនេះ គឺដើម្បីកាត់បន្ថយការបង្ខូច និងឧបសគ្គដល់ពាណិជ្ជកម្ម និងវិនិយោគ ដោយលើកកម្ពស់សមាហរណកម្មសេដ្ឋកិច្ចកាន់តែស៊ីជម្រៅ និងកិច្ចសហប្រតិបត្តិការ តាមរយៈការបង្កើតការប្រើប្រាស់ ការការពារ និងការអនុវត្តសិទ្ធិកម្មសិទ្ធិបញ្ញាឱ្យបានសមស្រប និងប្រកបដោយប្រសិទ្ធភាព។





សម្រាប់គោលបំណងនៃជំពូកនេះ " កម្មសិទ្ធិបញ្ញា " សំដៅដល់សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល ម៉ាក ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គំនូរឧស្សាហកម្ម ប្រកាសនីយបត្រតក្កកម្ម (ប័ណ្ណប៉ាតង់) គំនូសបង្ហាញនៃសៀគ្វីបង្រួម កិច្ចការពារសិទ្ធិពូជដំណាំ និងកិច្ចការងារព័ត៌មានមិនបង្ហាញ ដូចមានចែកក្នុងកថាខណ្ឌទី១ ដល់ទី៧ នៃផ្នែកទី២ នៃកិច្ចព្រមព្រៀងទិដ្ឋភាពពាណិជ្ជកម្មពាក់ព័ន្ធកម្មសិទ្ធិបញ្ញា (TRIPS)។



ដោយពិចារណាលើការមកដល់នៃយុគសម័យឌីជីថល ជំពូកនេះ រួមបញ្ចូលបទប្បញ្ញត្តិ "ទំនើបកម្ម" ដូចជាឯកសារទាក់ទងនឹងការដាក់ពាក្យសុំអេឡិចត្រូនិកជាកាតព្វកិច្ចវិធានការការពារបច្ចេកវិទ្យា និងការអនុវត្តសិទ្ធិឌីជីថល។



ជំពូកនេះក៏គ្របដណ្តប់លើទិដ្ឋភាពសង្គមពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញាដោយមានបទប្បញ្ញត្តិស្តីពីការការពារពូជរុក្ខជាតិ សុខភាពសាធារណៈ និងធនធានហ្សែនទិច ចំណេះដឹងប្រពៃណី និងវប្បធម៌។

## ៣.៣.១០ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

### គោលដៅនៃជំពូកនេះ គឺ៖

- លើកកម្ពស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករវាងភាគីសមាជិក និងការប្រើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឱ្យបានកាន់តែទូលំទូលាយជាសកល
- រួមចំណែកបង្កើតបរិយាកាសនៃភាពជឿជាក់និងទំនុកចិត្ត ក្នុងការប្រើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បង្កើនកិច្ចសហប្រតិបត្តិការរវាងភាគីសមាជិក ក្នុងការអភិវឌ្ឍពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ដោយមានការទទួលស្គាល់លើការផ្លាស់ប្តូរលំនាំពាណិជ្ជកម្ម ប្រទេសដែលចូលរួមក្នុងការចរចាកិច្ចព្រមព្រៀងអាសិបបានធានាថា កិច្ចព្រមព្រៀងនេះមានបញ្ចូលជំពូកស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលមានគោលបំណងជំរុញការប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងកិច្ចសហប្រតិបត្តិការក្នុងចំណោមបណ្តាភាគី។





ជំពូកនេះ ដាក់ចេញនូវបទប្បញ្ញត្តិដែលជំរុញឱ្យភាគីអាសិប កែលម្អរដ្ឋបាល និងដំណើរការពាណិជ្ជកម្មដោយប្រើមធ្យោបាយអេឡិចត្រូនិក

ជំពូកនេះ តម្រូវឱ្យភាគីទាំងអស់អនុម័ត ឬរក្សាក្របខ័ណ្ឌច្បាប់ ដើម្បីធានាការការពារព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ពាណិជ្ជកម្មតាមអេឡិចត្រូនិក ក៏ដូចជាមានក្របខ័ណ្ឌច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់តាមអ៊ីនធឺណែត។

ភាគីអាសិប ក៏បានយល់ព្រមរក្សាការអនុវត្តបច្ចុប្បន្ននៃការមិនអនុវត្តពន្ធគយសម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ស្របតាមសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីអង្គការពាណិជ្ជកម្មពិភពលោក។

## ៣.៣.១១ ការប្រកួតប្រជែង




ជំពូកនេះ ផ្តល់នូវក្របខ័ណ្ឌសម្រាប់បណ្តាភាគីទាំងអស់ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការលើការប្រកួតប្រជែង និងច្បាប់ដោយមានគោលបំណងលើកកម្ពស់ប្រសិទ្ធភាពសេដ្ឋកិច្ច និងសុខុមាលភាពអ្នកប្រើប្រាស់ ដោយផ្តល់កាតព្វកិច្ចដល់ភាគីក្នុងការបង្កើត ឬរក្សាច្បាប់ប្រកួតប្រជែង និងអាជ្ញាធរដែលហាមឃាត់សកម្មភាពប្រឆាំងនឹងការប្រកួតប្រជែង បទប្បញ្ញត្តិស្តីពីការផ្លាស់ប្តូរព័ត៌មាន និងការសម្របសម្រួលក្នុងសកម្មភាពអនុវត្តច្បាប់ ដែលការទទួលស្គាល់សិទ្ធិអធិបតេយ្យភាពរបស់ភាគីនីមួយៗ ដើម្បីអភិវឌ្ឍ និងអនុវត្តច្បាប់ប្រកួតប្រជែងរបស់ខ្លួន ក៏ដូចជាភាពខុសគ្នានៃសមត្ថភាពរបស់ភាគី និងកម្រិតនៃការអភិវឌ្ឍនៅក្នុងតំបន់នេះ។

ជំពូកនេះ ផ្តល់ជូនបន្ថែមទៀតសម្រាប់ការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនៃការប្រកួតប្រជែងដល់អ្នកពាក់ព័ន្ធទាំងអស់ ដែលចូលរួមក្នុងសកម្មភាពពាណិជ្ជកម្ម ហើយរាល់ការលើកលែង ឬការលើកលែងពីការអនុវត្តច្បាប់និងបទប្បញ្ញត្តិនានា មិនត្រឹមតែមានតម្លាភាព ហើយក៏ផ្អែកលើមូលដ្ឋាននៃគោលនយោបាយសាធារណៈ ឬផលប្រយោជន៍សាធារណៈផងដែរ។






ជំពូកនេះ ក៏ផ្តល់ផងដែរដល់បណ្តាភាគី ដើម្បីអនុវត្តសកម្មភាពសហប្រតិបត្តិការបច្ចេកទេស ដើម្បីកសាងសមត្ថភាពចាំបាច់ សំដៅពង្រឹងការអភិវឌ្ឍគោលនយោបាយនៃការប្រកួតប្រជែង និងការអនុវត្តច្បាប់នៃការប្រកួតប្រជែង។

ការការពារអ្នកប្រើប្រាស់ក៏ត្រូវបានដាក់បញ្ចូលក្នុងជំពូកដោយមានការសន្យាក្នុងការអនុម័ត ឬរក្សាច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុក ដើម្បីរារាំងការអនុវត្តពាណិជ្ជកម្មមិនស្មើភាព ឬការពណ៌នាមិនត្រឹមត្រូវ ឬការបំភាន់ក្នុងពាណិជ្ជកម្ម ការធ្វើឱ្យប្រសើរឡើងនូវការយល់ដឹង ការបើកឱ្យប្រើប្រាស់យន្តការការពារសម្រាប់អ្នកប្រើប្រាស់ និងការសហការលើបញ្ហាដែលមានផលប្រយោជន៍ទៅវិញទៅមកទាក់ទងនឹងការការពារអ្នកប្រើប្រាស់។




## ៣.៣.១២ សហគ្រាសធុនតូច និងមធ្យម



ភាគីនៃកិច្ចព្រមព្រៀងអាសិបទាំងអស់ ទទួលស្គាល់សក្តានុពលនៃសហគ្រាសធុនតូច និងមធ្យម រួមទាំងសហគ្រាសមីក្រូ ក្នុងការរួមចំណែកយ៉ាងសំខាន់ក្នុងកំណើនសេដ្ឋកិច្ច ការងារ និងនវានុវត្តន៍ដែលតាមរយៈនេះ ក៏ទទួលស្គាល់ផងដែរនូវតម្រូវការឱ្យមានថ្នាលដែលអាចអនុវត្តកម្មវិធីសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច និងសកម្មភាពសេដ្ឋកិច្ចនានា សំដៅបង្កើនសមត្ថភាពរបស់សហគ្រាសធុនតូច និងមធ្យម ក្នុងការប្រើប្រាស់ និងទាញប្រយោជន៍ពីកាលានុវត្តភាពកើតចេញពីកិច្ចព្រមព្រៀងអាសិប ដូចជាការធ្វើសមាហរណកម្មចូលក្នុងនិន្នាការខ្សែច្រវាក់ផ្គត់ផ្គង់តំបន់ជាដើម។



កិច្ចព្រមព្រៀងនេះ ផ្តោតសំខាន់លើសារៈសំខាន់នៃការចែករំលែកព័ត៌មាននានាពាក់ព័ន្ធកិច្ចព្រមព្រៀងអាសិប ដែលទាក់ទងនឹងសហគ្រាសធុនតូច និងមធ្យម រួមទាំងអត្ថបទទាំងស្រុងនៃកិច្ចព្រមព្រៀងនេះ ច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធពាណិជ្ជកម្ម និងការវិនិយោគដែលទាក់ទងនឹងសហគ្រាសធុនតូចនិងមធ្យម និងព័ត៌មានផ្សេងៗទៀតពាក់ព័ន្ធធុរកិច្ចដែលមានអត្ថប្រយោជន៍សម្រាប់សហគ្រាសធុនតូចនិងមធ្យមក្នុងការចូលរួម និងទាញប្រយោជន៍ពីកិច្ចព្រមព្រៀងអាសិបនេះ។

## ៣.៣.១៣ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស

ជំពូកនេះ ចែងអំពីទិដ្ឋភាពអភិវឌ្ឍន៍នៃកិច្ចព្រមព្រៀងអាសិបលើការបង្រួមគម្លាតអភិវឌ្ឍន៍ក្នុងចំណោមភាគីទាំងអស់ និងធ្វើភាគគីទាំងអស់អាចទទួលបានប្រយោជន៍ជាអតិបរមាពីការអនុវត្ត និងប្រើប្រាស់កិច្ចព្រមព្រៀងអាសិបនេះ។

ជំពូកនេះ ក៏ដើរតួជាថ្នាលសម្រាប់អនុវត្តកម្មវិធីជំនួយបច្ចេកទេស និងលើការប្រើប្រាស់កិច្ចព្រមព្រៀងនេះយ៉ាងមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងប្រកបដោយបរិយាប័ន្ន




ជាពិសេសក្នុងវិស័យដូចជា ពាណិជ្ជកម្មទំនិញ ពាណិជ្ជកម្មសេវាកម្ម វិនិយោគកម្មសិទ្ធិបញ្ញា ការប្រកួតប្រជែង សហគ្រាសធុនតូចនិងមធ្យម និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ផ្តល់អាទិភាពដោះស្រាយតម្រូវការនានារបស់ភាគីជាប្រទេសអភិវឌ្ឍន៍តិចតួចទាំងអស់។

ព័ត៌មានលម្អិតទាក់ទងនឹងកិច្ចព្រមព្រៀងអាសិប អាចស្វែងរកបានតាមរយៈតំណភ្ជាប់ខាងក្រោម៖
https://www.moc.gov.kh/official-documents?category_id=6



**ព័ត៌មានបន្ថែមពាក់ព័ន្ធអត្ថបទលម្អិតផ្លូវការសូមទំនាក់ទំនងមក**


https://www.moc.gov.kh/

ក្រសួងពាណិជ្ជកម្ម Ministry of Commerce

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា
ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជណាចក្រកម្ពុជា

ទូរស័ព្ទ/ទូរសារ៖ (៨៥៥) ២៣ ៨៦៦ ៤៦៩

Australian Aid

CAVAC
Innovation
In Agriculture